# សូមនាំយកមកអោយសហគមន៍អ្នក នូវចំណែករបស់ខ្លួនពីថវិការដ្ឋដែលមានចំនួនជាង ៤០០ពាន់លានដុល្លារក្នុងមួយឆ្នាំ។

**សូមឆ្លើយទៅនឹង១០សំនួរក្នុងរយៈពេល១០នាទី ដើម្បីជួយសហគមន៍អ្នក។**

## ជំរឿនប្រជាជនៈ សេចក្តីសង្ខេប

- **អ្វីៈ** ជំរឿនប្រជាជនគឺជាការរាប់ចំនួនមនុស្សគ្រប់រូបដែលមានទីលំនៅ នៅក្នុងសហរដ្ឋអាមេរិក។
- **អ្នកណាៈ** អ្នកដែលមានទីលំនៅ នៅក្នុងសហរដ្ឋអាមេរិកទាំងអស់ ត្រូវតែបានរាប់ - ទាំងអ្នកមានសញ្ជាតិ និងមិនមានសញ្ជាតិអាមេរិក។
- **ពេលណាៈ** អ្នកនឹងបានទទួលបញ្ជីសំនួររបស់អ្នកក្នុងខែមិនាឆ្នាំ២០១០ តាមរយៈប្រៃសណីយ៍សហរដ្ឋ ឬក៏តាមការចែកជូនដោយផ្ទាល់។ ប្រជាជនមួយចំនួនដែលនៅឆ្ងាយដាច់ស្រយាលនឹងត្រូវបានគេរាប់ដោយផ្ទាល់តែម្តង។
- **ហេតុអ្វីៈ** រដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកតម្រូវអោយធ្វើជំរឿនជាតិរៀងរាល់ដប់ឆ្នាំម្តង ដើម្បីរាប់ចំនួនប្រជាជន និងកំណត់ចំនួនអាសនៈដែលរដ្ឋនិមួយៗនឹងមាននៅក្នុងរដ្ឋសភាសហរដ្ឋ។
- **ដូចម្តេចៈ** គ្រួសារនិមួយៗត្រូវតែបំពេញបញ្ជីសំនួររបស់ខ្លួន ហើយផ្ញើត្រឡប់ទៅវិញ នៅពេលដែលបានទទួលបញ្ជីសំនួរនោះ។ គ្រួសារណាដែលមិនឆ្លើយតប អាចនឹងទទួលបញ្ជីសំនួរជំនួសថ្មីមួយទៀតនៅដើមខែមេសា។ អ្នកធ្វើជំរឿនប្រជាជននឹងចុះទៅជួបគ្រួសារណា ដែលមិនបានផ្ញើបញ្ជីសំនួរត្រឡប់ទៅវិញ ដើម្បីធ្វើការរាប់ដោយផ្ទាល់។

## ការរាប់ទាំងស្រុងៈ សារៈសំខាន់នៃទិន្នន័យជំរឿនប្រជាជន

- ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលសហព័ន្ធបែងចែកថវិកាជាង៤០០ពាន់លានដុល្លារ អោយរដ្ឋ និងសហគមន៍នានា។ ការបែងចែកនេះមួយផ្នែក គឺផ្អែកទៅលើទិន្នន័យជំរឿនប្រជាជន។
- ទិន្នន័យជំរឿនប្រជាជនជួយណែនាំអ្នកធ្វើការសម្រេចចិត្តនានាតាមមូលដ្ឋាន ពីកន្លែងណាដែលត្រូវសាងសង់សាលារៀនថ្មី ផ្លូវថ្មី មជ្ឈមណ្ឌលសុខភាព មជ្ឈមណ្ឌលថែទាំកុមារ និងមនុស្សចាស់ និងសំណង់ផ្សេងៗទៀតសំរាប់សហគមន៍។
- ទិន្នន័យជំរឿនប្រជាជនកំណត់នូវព្រំប្រទល់នៃការបែងចែកមណ្ឌលនីតិបញ្ញត្តិតាមមូលដ្ឋាន និងតាមរដ្ឋ និងមណ្ឌលសភា។

## បញ្ជីសំនួរជំរឿនប្រជាជនឆ្នាំ ២០១០ៈ ងាយស្រួល មានសារៈសំខាន់ និងមានសុវត្ថិភាព

- បញ្ជីសំនួរជំរឿនប្រជាជនឆ្នាំ២០១០មានតែ១០សំនួរប៉ុណ្ណោះ ហើយត្រូវការពេលប្រហែលតែ១០នាទីដើម្បីបំពេញ។ សមាជិកគ្រួសារនិមួយៗតម្រូវអោយផ្តល់ព័ត៌មានសំខាន់ៗស្តីអំពីប្រជាសាស្ត្រដូចជា៖ ផ្ទះដែលនៅសព្វថ្ងៃជាផ្ទះជួលឬក៏ជាផ្ទះកម្មសិទ្ធិផ្ទាល់ខ្លួន អាសយដ្ឋាន ឈ្មោះ ភេទ អាយុ និង ជាតិសាសន៍ របស់សមាជិកគ្រួសារផ្សេងទៀត ដែលរស់នៅជាមួយ។
- តាមច្បាប់ ការិយាល័យជំរឿនប្រជាជនមិនអាចចែកចាយចម្លើយជំរឿនប្រជាជនរបស់បុគ្គលម្នាក់ទៅអោយអ្នកណាបានឡើយ រួមទាំងក្រសួងផ្សេងៗទៀតនៃរដ្ឋាភិបាលសហព័ន្ធ និងអង្គភាពអនុវត្តច្បាប់នានា។

United States Census 2010

ជំរឿនប្រជាជនសហរដ្ឋ

**គឺពឹងលើយើងទាំងស្រុង**

## ប្រវត្តិនៃជំរឿនប្រជាជន

ជំរឿនប្រជាជនលើកទីមួយធ្វើឡើងក្នុងឆ្នាំ១៧៩០ ដើម្បីកំណត់ចំនួនអាសនៈដែលរដ្ឋនិមួយៗត្រូវមានក្នុងរដ្ឋសភាសហរដ្ឋ។ ជំរឿនប្រជាជនក៏ត្រូវបង្កើតឡើងដើម្បីអោយមានការយល់ដឹងកាន់តែច្បាស់ថាតើប្រជាជនរស់នៅកន្លែងណាខ្លះ និងដើម្បីបង្កើតបទដ្ឋាននៃការតាំងទីលំនៅ នៅពេលដែលប្រទេសនេះកាន់តែរីកធំឡើង។

## អំពីការិយាល័យជំរឿនប្រជាជន

ការិយាល័យជំរឿនប្រជាជនត្រូវបានបង្កើតឡើងនៅឆ្នាំ១៩០២។ បច្ចុប្បន្ននេះ ក្រៅពីការគ្រប់គ្រងជំរឿនប្រជាជន និងលំនៅដ្ឋាន ការិល័យជំរឿនប្រជាជនធ្វើការស្ទង់មតិប្រចាំឆ្នាំជាង២០០ទៀត នេះគឺរាប់បញ្ចូលទាំងការស្ទង់មតិសហគមន៍អាមេរិក (American Community Survey) ការស្ទង់មតិចំនួនប្រជាជនបច្ចុប្បន្ន និងជំរឿនសេដ្ឋកិច្ចជាច្រើនទៀតរៀងរាល់៥ឆ្នាំម្តង។



សូមផ្ញើទំរង់ជំរឿនប្រជាជនរបស់អ្នកត្រឡប់ទៅវិញថ្ងៃនេះ។

# កាលបរិច្ឆេទសំខាន់ៗនៃជំរឿនប្រជាជនឆ្នាំ ២០១០

***ខែកុម្ភៈ – ខែមិនា ឆ្នាំ២០១០***

បញ្ជីសំនួរជំរឿនប្រជាជនត្រូវបានផ្ញើចេញ ឬក៏ចែកចាយទៅតាមលំនៅដ្ឋាន។

***ខែមិនា – ខែមេសា ឆ្នាំ២០១០***

កម្មវិធី "ត្រូវបានរាប់"(Be Counted) នឹងត្រូវអនុវត្ត។ បញ្ជីសំនួរជំរឿនប្រជាជននឹងមានដាក់នៅតាមកន្លែងសាធារណៈមួយចំនួន សំរាប់អ្នកដែលមិនបានទទួលបញ្ជីសំនួរនេះតាមប៉ុស្តិ៍។

***ថ្ងៃទី១ ខែមេសា ឆ្នាំ២០១០***

ថ្ងៃជំរឿនប្រជាជន។

***ខែឧសភា – ខែកក្កដា ឆ្នាំ២០១០***

អ្នកធ្វើជំរឿនប្រជាជនចុះទៅតាមលំនៅដ្ឋានដែលមិនបានផ្ញើបញ្ជីសំនួរត្រឡប់មកវិញ។

***ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១០***

តាមច្បាប់ ការិយាល័យជំរឿនប្រជាជនយកការរាប់ចំនួនប្រជាជនទៅជូនប្រធានាធិបតី។

***ខែមិនា ឆ្នាំ២០១១***

តាមច្បាប់ ការិយាល័យជំរឿនប្រជាជនបញ្ចប់នូវការផ្ដល់ជូនទិន្នន័យនៃការបែងចែកសង្កាត់ឡើងវិញទៅអោយរដ្ឋនានា។

# សំនួរនិងចម្លើយ

**១. ស. តើអ្នកណាខ្លះដែលត្រូវបំពេញបញ្ជីសំនួរជំរឿនប្រជាជន?**

**ច.** បុគ្គលដែលមានឈ្មោះជាអ្នកជួលផ្ទះ ឬក៏មានឈ្មោះជាម្ចាស់ផ្ទះត្រូវបំពេញបញ្ជីសំនួរជំនួសអោយមនុស្សទាំងអស់ដែលរស់នៅក្នុងផ្ទះ គឺរាប់បញ្ចូលទាំងសាច់ញាតិ និងមិនមែនសាច់ញាតិ។

**២. ស. តើជំរឿនប្រជាជនឆ្នាំ២០១០ ខុសគ្នាពីជំរឿនប្រជាជនមុនៗដូចម្តេចខ្លះ?**

**ច.** នៅក្នុងឆ្នាំ២០១០ គេហដ្ឋាននិមួយៗនឹងបានទទួលបញ្ជីសំនួរខ្លីមួយដែលមានតែ១០សំនួរប៉ុណ្ណោះ។ ព័ត៏មានពិស្តារអំពីសេដ្ឋកិច្ចសង្គម ដែលធ្លាប់បានប្រមូលតាមរយៈជំរឿនប្រជាជនរៀងរាល់១០ឆ្នាំម្តង នឹងត្រូវលើកយកទៅសាកសួរប្រជាជនតែមួយភាគតូចប៉ុណ្ណោះ តាមរយៈការស្ទង់មតិសហគមន៍អាមេរិក(American Community Survey) ប្រចាំឆ្នាំវិញម្តង។ ព័ត៏មានបន្ថែមអំពីការស្ទង់មតិសហគមន៍អាមេរិកនេះសូមទៅបើកមើលនៅwww.census.gov

**៣. ស. តើទិន្នន័យជំរឿនប្រជាជននឹងត្រូវយកទៅប្រើប្រាស់ដូចម្តេចដែរ?**

**ច.** ទិន្នន័យជំរឿនប្រជាជនកំណត់ចំនួនអាសនៈដែលរដ្ឋនិមួយៗនឹងមាននៅក្នុងរដ្ឋសភាសហរដ្ឋ។ ទិន្នន័យជំរឿនប្រជាជនក៏អាចជួយកំណត់ការបែងចែកថវិការដ្ឋសហព័ន្ធ សំរាប់សេវាកម្មសហគមន៍ ដូចជាកម្មវិធីអាហារថ្ងៃត្រង់នៅតាមសាលារៀន មជ្ឈមណ្ឌលថែទាំមនុស្សចាស់ និងសំណង់ថ្មីៗដូចជា ផ្លូវ(highways) និងមន្ទីរពេទ្យជាដើម។

**៤. ស. តើមានជំនួយបែបណាខ្លះដើម្បីជួយប្រជាជនបំពេញបញ្ជីសំនួរ?**

**ច.** សេចក្តីជំនួយណែនាំអំពីបញ្ជីសំនួរជំរឿនប្រជាជនឆ្នាំ២០១០ មានជាច្រើនភាសា។ មជ្ឈមណ្ឌលជំនួយការខាងផ្នែកបញ្ជីសំនួរ Questionnaire Assistance Centers (QAC) ក៏នឹងជួយអ្នកដែលមិនអាចអានឬក៏យល់បញ្ជីសំនួរនេះផងដែរ។ បញ្ជីសំនួរដែលបោះពុម្ពជាអក្សរធំៗសំរាប់អ្នកដែលងងឹតភ្នែក មានទុកបំរុងជូននៅពេលដែលអ្នកធ្វើការស្នើសុំ ហើយក៏មានកម្មវិធី ធី-ឌី-ឌី Teletext Device for the Deaf (TDD) សំរាប់ជួយមនុស្សថ្លង់ផងដែរ។ សូមទាក់ទងមជ្ឈមណ្ឌលជំរឿនប្រជាជននៅតាមតំបន់របស់អ្នក ដើម្បីស្វែងរកព័ត៏មានលំអិតអំពីប្រភេទនៃជំនួយការដែលមាន និងដើម្បីរកទីតាំងនៃQAC។

**៥. ស. តើការិយាល័យជំរឿនប្រជាជនរាប់មនុស្សដែលគ្មានទីលំនៅជាអចិន្ត្រៃយ៍យ៉ាងដូចម្តេចដែរ?**

**ច.** បុគ្គលិកការិយាល័យជំរឿនប្រជាជនទទួលធ្វើប្រតិបត្តិការដ៏ធំធេង ដើម្បីចុះទៅរាប់ដោយផ្ទាល់នូវប្រជាជនដែលរស់នៅជាក្រុមតាមកន្លែងនានាដូចជា អាគារសំរាប់និស្សិតស្នាក់នៅ បន្ទាយទាហាន មន្ទីរថែទាំមនុស្សជរា និងជំរំជ្រកកោនបណ្តោះអាសន្ននានា ក៏ដូចជាប្រជាជនដែលត្រូវជម្លៀសដោយគ្រោះមហន្តរាយធម្មជាតិ។

**ព័ត៏មានបន្ថែមស្តីអំពីជំរឿនប្រជាជនឆ្នាំ២០១០ សូមទៅបើកមើលនៅ 2010census.gov។**

United States Census 2010
ជំរឿនប្រជាជនសហរដ្ឋ
គឺពឹងលើយើងទាំងស្រុង

Issued August 2009 | Form D-3286 (KH)